

## ព័ត៌មានមូលដ្ឋានទាក់ទងនឹងវ៉ាក់សាំង

**តើវ៉ាក់សាំងជំងឺកូវីដ-១៩ គឺជាអ្វី ហើយដំណើរការយ៉ាងដូចម្តេច?**

គិតត្រឹមខែមីនា ឆ្នាំ2021 មានវ៉ាក់សាំងជំងឺកូវីដ-១៩
ចំនួនបីប្រភេទដែលទទួលបានការអនុញ្ញាតឱ្យប្រើប្រាស់ដោយរដ្ឋបាលចំណីអាហារ
និងឱសថរបស់សហព័ន្ធសហរដ្ឋអាមេរិក (FDA)។ ក្នុងនោះរួមមាន៖

- វ៉ាក់សាំងជំងឺកូវីដ-១៩ ប្រភេទ Pfizer-BioNTech ដែលទទួលបានការអនុម័តនៅថ្ងៃទី11 ខែធ្នូ ឆ្នាំ2020។
- វ៉ាក់សាំងជំងឺកូវីដ-១៩ ប្រភេទ Moderna ដែលទទួលបានការអនុម័តនៅថ្ងៃទី18 ខែធ្នូ ឆ្នាំ2020
- វ៉ាក់សាំងជំងឺកូវីដ-១៩ ប្រភេទ Johnson & Johnson ដែលទទួលបានការអនុម័តនៅថ្ងៃទី27 ខែកុម្ភៈ ឆ្នាំ2021។

វ៉ាក់សាំងជំងឺកូវីដ-១៩ គឺជាប្រភេទថ្នាំដែលធ្វើការដោយបង្រៀនរាងកាយរបស់យើងឲ្យស្គាល់
និងប្រយុទ្ធប្រឆាំងជាមួយវីរុសដែលបណ្តាលឱ្យមានជំងឺកូវីដ-១៩។ វ៉ាក់សាំងជំងឺកូវីដ-១៩
នឹងជួយការពារយើងពីការឈឺ ហើយជួយបញ្ចប់ការរាតត្បាត។

**តើមានវ៉ាក់សាំងផ្សេងទៀតដែរឬទេ?**

មាន ។ បើគិតត្រឹមថ្ងៃទី28 ខែធ្នូ ឆ្នាំ2020 ការធ្វើតេស្តសាកល្បងទ្រង់ទ្រាយធំត្រូវបានគ្រោងទុក
ឬកំពុងដំណើរការសម្រាប់វ៉ាក់សាំងជំងឺកូវីដ-១៩ ចំនួនពីរប្រភេទនៅក្នុងសហរដ្ឋអាមេរិក៖

- វ៉ាក់សាំងជំងឺកូវីដ-១៩ ប្រភេទ AstraZeneca
- វ៉ាក់សាំងជំងឺកូវីដ-១៩ ប្រភេទ Novavax

**តើវ៉ាក់សាំងជំងឺកូវីដ-១៩ បច្ចុប្បន្នត្រូវបានអនុម័តសម្រាប់កុមារដែរឬទេ?**

អត់ទេ មិនទាន់មានវ៉ាក់សាំងជំងឺកូវីដ-១៩ ប្រភេទណាមួយដែលត្រូវបានអនុម័តសម្រាប់កុមារដែល
មានអាយុតិចជាង 16 ឆ្នាំឡើយ។ យើងនៅតែមិនទាន់ដឹងថាតើពេលណាទើបវ៉ាក់សាំងជំងឺកូវីដ-១៩
ទទួលបានការអនុម័តសម្រាប់កុមារនោះទេ ប៉ុន្តែយើងដឹងថាវ៉ាក់សាំងប្រភេទ Pfizer និង Moderna
កំពុងតែធ្វើតេស្តសាកល្បងវ៉ាក់សាំងរបស់ពួកគេលើកុមារដែលមានអាយុនៅចន្លោះពី 12 ទៅ 17 ឆ្នាំ។

## ការបង្កើត និងសុវត្ថិភាពនៃវ៉ាក់សាំង

**តើដំណើរការនៃការបង្កើតវ៉ាក់សាំងជំងឺកូវីដ-១៩ មានអ្វីខ្លះ?**

ដំណើរការនៃការបង្កើតវ៉ាក់សាំងជំងឺកូវីដ-១៩
និងវ៉ាក់សាំងផ្សេងទៀតដែលកំពុងតែដំណើរការទាមទារឱ្យមានការធ្វើតេស្តយ៉ាងម៉ត់ចត់ទៅលើអ្នកចូល
រួមរាប់ពាន់នាក់ក្នុងពេលធ្វើតេស្តសាកល្បង។ នៅពេលដែលមានព័ត៌មានគ្រប់គ្រាន់
រដ្ឋបាលចំណីអាហារ និងឱសថអាមេរិក (FDA) ជាអ្នកកំណត់ហានិភ័យ និងអត្ថប្រយោជន៍
ហើយធ្វើការណែនាំ ឬបដិសេធការអនុម័តវ៉ាក់សាំង មុនពេលផ្តល់វ៉ាក់សាំងដល់សាធារណជន។
រដ្ឋបាលចំណីអាហារ និងឱសថអាមេរិក (FDA) គឺជាភ្នាក់ងារដែលទទួលខុសត្រូវក្នុងការធានាសុវត្ថិភាព
និងប្រសិទ្ធភាពនៃវ៉ាក់សាំងជំងឺកូវីដ-១៩ នៅក្នុងសហរដ្ឋអាមេរិក។
វ៉ាក់សាំងជំងឺកូវីដ-១៩
ដែលទទួលបានការអនុញ្ញាតថ្មីៗនេះទទួលបានការអនុញ្ញាតដោយរដ្ឋបាលចំណីអាហារ
និងឱសថអាមេរិក (FDA) ដោយផ្អែកលើការធ្វើតេស្តសាកល្បង
ហើយគោលការណ៍ណែនាំត្រូវបានអនុវត្តដើម្បីធានាថាវ៉ាក់សាំងទាំងនេះមានសុវត្ថិភាពសម្រាប់ប្រើប្រាស់។
រដ្ឋបាលចំណីអាហារ និង ឱសថអាមេរិក (FDA) និងបន្តពិនិត្យ
និងតាមដានផលប៉ះពាល់កើតមានជាធម្មតាសម្រាប់វ៉ាក់សាំងថ្មី។



**តើវ៉ាក់សាំងជំងឺកូវីដ-១៩ អាចចម្លងវីរុសបានដែរឬទេ?**
ទេ វ៉ាក់សាំងជំងឺកូវីដ-១៩ ដែលទទួលបានការអនុញ្ញាតថ្មីៗនេះ និងវ៉ាក់សាំងជំងឺកូវីដ-១៩ ផ្សេងទៀតដែលកំពុងដំណើរការមិនអាចចម្លងជំងឺកូវីដ-១៩ ដល់យើងទេ។ ផ្ទុយទៅវិញ វ៉ាក់សាំងជំងឺកូវីដ-១៩ នឹងជួយការពារយើងពីការឈឺ ដោយជួយឱ្យរាងកាយរបស់យើងបង្កើតនូវភាពស៊ាំចាំបាច់ដើម្បីប្រយុទ្ធប្រឆាំងនឹងវីរុសប្រសិនបើយើងឆ្លងមេរោគ។

**តើវ៉ាក់សាំងជំងឺកូវីដ-១៩ មានផ្ទុកវីរុសមានជីវិតដែលបង្កឱ្យមានជំងឺកូវីដ-១៩ ដែរឬទេ?**
អត់ទេ វ៉ាក់សាំងជំងឺកូវីដ-១៩ ដែលទទួលបានការអនុញ្ញាតថ្មីៗនេះ និងវ៉ាក់សាំងជំងឺកូវីដ-១៩ ដែលកំពុងដំណើរការផ្សេងទៀត មិនមានផ្ទុកវីរុសមានជីវិតដែលបណ្តាលឱ្យឆ្លងជំងឺកូវីដ-១៩ ទេ។ ដូចដែលបានរៀបរាប់កន្លងមក វ៉ាក់សាំងជំងឺកូវីដ-១៩ គឺជាថ្នាំមួយប្រភេទដែលបង្រៀនរាងកាយរបស់យើងឱ្យបង្កើតយន្តការចាំបាច់ដើម្បីសម្គាល់ និងប្រយុទ្ធប្រឆាំងជាមួយវីរុសប្រសិនបើយើងឆ្លងមេរោគ។

**តើនរណាជាអ្នកបញ្ជាក់ថាវ៉ាក់សាំងជំងឺកូវីដ-១៩ មានសុវត្ថិភាព?**
រដ្ឋបាលចំណីអាហារ និងឱសថអាមេរិក (FDA) និងមជ្ឈមណ្ឌលការពារ និងបង្ការជំងឺ (CDC) ជាអ្នកធានាថាវ៉ាក់សាំងជំងឺកូវីដ-១៩ ដែលទទួលបានការអនុញ្ញាតថ្មីៗនេះ និងវ៉ាក់សាំងផ្សេងទៀតដែលកំពុងដំណើរការ មានសុវត្ថិភាព និងប្រសិទ្ធភាពសម្រាប់សហគមន៍របស់យើង។ រដ្ឋបាលចំណីអាហារ និង ឱសថអាមេរិក (FDA) វាយតម្លៃដោយប្រុងប្រយ័ត្ននូវរាល់ព័ត៌មានទាំងអស់ដែលមានពីវ៉ាក់សាំងដើម្បីកំណត់ពីសុវត្ថិភាព និងប្រសិទ្ធភាពរបស់វា។ បន្ទាប់ពីរដ្ឋបាលចំណីអាហារ និងឱសថអាមេរិក (FDA) អនុញ្ញាតឱ្យប្រើប្រាស់វ៉ាក់សាំងណាមួយ មជ្ឈមណ្ឌលការពារ និងបង្ការជំងឺ (CDC) នឹងត្រួតពិនិត្យនូវរាល់ព័ត៌មានពាក់ព័ន្ធជាមួយវ៉ាក់សាំងជំងឺកូវីដ-១៩ មុនពេលផ្តល់ការណែនាំសម្រាប់ការប្រើប្រាស់ជាសាធារណៈ។

**តើខ្ញុំអាចដឹងបានដោយរបៀបណាថាវ៉ាក់សាំងជំងឺកូវីដ-១៩ មានសុវត្ថិភាព និងប្រសិទ្ធភាព បើវ៉ាក់សាំងត្រូវបានបង្កើតក្នុងរយៈពេលលឿនយ៉ាងនេះ?**
រដ្ឋបាលចំណីអាហារ និងឱសថអាមេរិក(FDA) ធានាថាវ៉ាក់សាំងទាំងអស់មានសុវត្ថិភាពបំផុតតាមដែលអាចធ្វើទៅបាន ហើយដោយសារតែវ៉ាក់សាំងត្រូវបានផ្តល់ឱ្យមនុស្សដែលមានសុខភាពល្អរាប់លាននាក់ដើម្បីការពារជំងឺធ្ងន់ធ្ងរ វ៉ាក់សាំងទាំងអស់ត្រូវបានអនុវត្តទៅតាមស្តង់ដារសុវត្ថិភាពខ្ពស់បំផុត។ វ៉ាក់សាំងជំងឺកូវីដ-១៩ បានឆ្លងកាត់ការធ្វើតេស្តសាកល្បងយ៉ាងម៉ត់ចត់ ដែលរួមបញ្ចូលទាំងការចាក់វ៉ាក់សាំងទៅលើមនុស្សរាប់ម៉ឺននាក់ដែលចូលរួមក្នុងការសិក្សា ដើម្បីប្រមូលព័ត៌មានចាំបាច់សម្រាប់រដ្ឋបាលចំណីអាហារ និងឱសថអាមេរិក(FDA) ក្នុងការកំណត់ពីសុវត្ថិភាព និងប្រសិទ្ធភាព។ សូម្បីតែបន្ទាប់ពីវ៉ាក់សាំងជំងឺកូវីដ-១៩ ត្រូវបានអនុម័តហើយក៏ដោយ រដ្ឋបាលចំណីអាហារ និងឱសថអាមេរិក (FDA) នៅតែបន្តតាមដានសុវត្ថិភាពសាធារណៈ។

**ប៉ុន្តែតើវ៉ាក់សាំងទាំងនេះត្រូវបានបង្កើតឡើងឆាប់រហ័សយ៉ាងនេះដោយរបៀបណា?**
អ្នកវិទ្យាសាស្រ្តនៅជុំវិញពិភពលោកបានផ្តល់អាទិភាពចម្បងដល់ការបង្កើតវ៉ាក់សាំងជំងឺកូវីដ-១៩ ដែលប្រកបដោយប្រសិទ្ធភាព ហើយបានប្រើប្រាស់បច្ចេកវិទ្យាមានស្រាប់ល្អបំផុត ដើម្បីទប់ទល់នឹងវីរុសប្រភេទថ្មីនេះ។ កិច្ចសហប្រតិបត្តិការអន្តរជាតិដែលមិនធ្លាប់មានពីមុនមក ការចែករំលែកធនធាន ការបង្កើនសមត្ថភាពផលិតកម្ម និងការផ្តល់មូលនិធិ បានអនុញ្ញាតឱ្យក្រុមហ៊ុនផលិតវ៉ាក់សាំងទាំងអស់បង្កើនល្បឿនផលិតកម្មវ៉ាក់សាំង។ រដ្ឋបាលចំណីអាហារ និងឱសថអាមេរិក (FDA) ក៏បានអនុញ្ញាតិឱ្យមានការធ្វើតេស្តសាកល្បងទាំងបីដំណាក់កាល



ចាប់ផ្ដើមដំណើរការក្នុងពេលដំណាលគ្នាជាជាងតាមលំដាប់លំដោយ ហើយបានធ្វើការយ៉ាងឆាប់រហ័សដើម្បីអនុញ្ញាតឱ្យមានការប្រើប្រាស់ក្នុងករណីអាសន្ន ខណៈពេលរក្សាការធ្វើតេស្តយ៉ាងតឹងរឹង ដើម្បីធានាថាវ៉ាក់សាំងដែលកំពុងដំណើរការមានសុវត្ថិភាព និងមានប្រសិទ្ធភាព។

**ហេតុអ្វីបានជាវ៉ាក់សាំងជំងឺកូវីដ-១៩ ដែលកំពុងដំណើរការមានច្រើនម្ល៉េះ?**

នៅលើពិភពលោកមានមនុស្សចំនួន 7 ពាន់លាននាក់ ហើយជំងឺកូវីដ-១៩ បានជះឥទ្ធិពលដល់គ្រប់ប្រទេសនៅគ្រប់ទ្វីបទាំងអស់។ នេះមានន័យថា យើងចាំបាច់ត្រូវមានវ៉ាក់សាំងច្រើនប្រភេទដើម្បីគ្រប់គ្រងជំងឺកូវីដ-១៩។ ដូចគ្នាផងដែរ យោងទៅតាមភាពចម្រុះជាតិសាសន៍នៃសហគមន៍របស់យើង ការមានចាក់វ៉ាក់សាំងច្រើនប្រភេទគឺជាវិធីសាស្ត្រល្អមួយដើម្បីបង្កើនឱកាសរបស់យើងក្នុងការស្វែងរកវ៉ាក់សាំងច្រើនជាងមួយប្រភេទ ដែលមានសុវត្ថិភាព ហើយមានប្រសិទ្ធភាពសម្រាប់មនុស្សគ្រប់គ្នា។

**ហេតុអ្វីបានជាខ្ញុំត្រូវការចាក់វ៉ាក់សាំងចំនួន 2 ដង?**

វ៉ាក់សាំងប្រភេទ Pfizer និង Moderna ទាមទារឱ្យមានការចាក់ពីរដងដើម្បីទទួលបានប្រសិទ្ធភាពល្អបំផុត។ ការចាក់លើកទីមួយជួយឱ្យរាងកាយរបស់យើងស្គាល់វីរុស ហើយត្រៀមប្រព័ន្ធការពារភាពស៊ាំរបស់យើងឱ្យរួចរាល់ ខណៈពេលដែលការចាក់លើកទីពីរនឹងជួយពង្រឹងការឆ្លើយតបនៃប្រព័ន្ធភាពស៊ាំ។ ប្រព័ន្ធការពារភាពស៊ាំរបស់យើងនឹងមានការកើនឡើងខ្ពស់ជាងមុនបន្ទាប់ពីចាក់លើកទីពីរ ពីព្រោះរាងកាយរបស់យើងបានត្រៀមខ្លួនរួចជាស្រាច់ ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។ វាពិតជាចាំបាច់ណាស់ក្នុងការរក្សាការណាត់ជួបលើកទីពីររបស់អ្នកឱ្យបានពេញលេញ។ មនុស្សមួយចំនួនអាចនឹងជួបប្រទះផលប៉ះពាល់ក្នុងរយៈពេលពីរបីថ្ងៃបន្ទាប់ពីការចាក់លើកទីមួយ ឬទាំងពីរលើក។ ប្រសិនបើអ្នកមានការព្រួយបារម្ភអំពីផលប៉ះពាល់ សូមទាក់ទងទៅកាន់អ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នក។

**តើវ៉ាក់សាំងអាចប្រៀបធៀបគ្នាយ៉ាងដូចម្ដេចខ្លះ?**

វ៉ាក់សាំងប្រភេទ Pfizer និង ប្រភេទ Moderna ប្រើបច្ចេកវិទ្យា messenger mRNA ដែលបង្រៀនរាងកាយរបស់យើងដើម្បីប្រយុទ្ធប្រឆាំងនឹងការឆ្លងជំងឺកូវីដ-១៩ តាមវិធីសាស្ត្រពីរយ៉ាង៖ ទីមួយ តាមរយៈការបញ្ឈប់វីរុស និងទីពីរ តាមរយៈការវាយប្រហារវីរុស។ វ៉ាក់សាំងទាំងពីរប្រភេទនេះផ្ដល់ការការពារល្អបំផុតប្រឆាំងនឹងជំងឺកូវីដ-១៩។ វ៉ាក់សាំងប្រភេទ Pfizer ទទួលបានការអនុញ្ញាតដោយរដ្ឋបាលចំណីអាហារ និងឱសថអាមេរិក (FDA) សម្រាប់មនុស្សដែលមានអាយុចាប់ពី 16 ឆ្នាំឡើងទៅ។ វ៉ាក់សាំងប្រភេទ Moderna គឺសម្រាប់មនុស្សដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ។ វ៉ាក់សាំងប្រភេទ Moderna និងវ៉ាក់សាំងប្រភេទ Pfizer/BioNTech តម្រូវឱ្យមានការចាក់វ៉ាក់សាំងចំនួនពីរដង។ ចន្លោះពេលសម្រាប់វ៉ាក់សាំងប្រភេទ Moderna គឺ 28 ថ្ងៃ ហើយចន្លោះពេលសម្រាប់វ៉ាក់សាំងប្រភេទ Pfizer គឺ 21 ថ្ងៃ។ លើសពីនេះទៀត វ៉ាក់សាំងរបស់ Moderna មានគុណសម្បត្តិជាច្រើន ហើយវាថែមទាំងអាចរក្សាទុកនៅក្នុងទូរទឹកកកធម្មតាបាន ដែលផ្ដល់ភាពងាយស្រួលក្នុងការចែកចាយ។



# ការចាក់វ៉ាក់សាំង

**តើនរណាដែលអាចចាក់វ៉ាក់សាំងបានមុនគេ?**

វ៉ាក់សាំងជំងឺកូវីដ-១៩ បច្ចុប្បន្នមានសម្រាប់៖

- អ្នកផ្ដល់សេវាថែទាំសុខភាព
- អ្នករស់នៅមជ្ឈមណ្ឌលស្នាក់នៅរយៈពេលវែង

គិតត្រឹមថ្ងៃទី22 ខែធ្នូ ឆ្នាំ2020 ក្រុមដែលទទួលបានអតិភាពដើម្បីទទួលបានការចាក់វ៉ាក់សាំងបន្ទាប់គឺ៖

- អ្នកធ្វើការមុខងារសំខាន់ ដូចជាអ្នកពន្លត់អគ្គិភ័យ មន្ត្រីប៉ូលីស មន្ត្រីមណ្ឌលកែតម្រូវបុគ្គលិកផ្នែកអាហារ និងកសិកម្ម បុគ្គលិកការិយាល័យប្រៃសណីយ៍សហរដ្ឋអាមេរិក បុគ្គលិកហាងលក់គ្រឿងទេស និងគ្រូបង្រៀន
- មនុស្សចាស់ដែលមានអាយុ 75 ឬចាស់ជាងនេះ

ក្រុមដែលមានអាទិភាពបន្ទាប់គឺ៖

- មនុស្សមានអាយុនៅចន្លោះពី 65-74 ឆ្នាំ ដោយសារតែពួកគេប្រឈមនឹងហានិភ័យខ្ពស់នៃការស្នាក់នៅមន្ទីរពេទ្យ
- មនុស្សដែលមានអាយុនៅចន្លោះពី 16-64 ឆ្នាំ ហើយមានបញ្ហាសុខភាពស្រាប់
- បុគ្គលិកមុខងារសំខាន់ដែលធ្វើការខាងដឹកជញ្ជូន សេវាកម្មអាហារ ខាងសំណង់ ព័ត៌មានបច្ចេកវិទ្យា សុវត្ថិភាពសាធារណៈ និងសុខភាពសាធារណៈ។

ទោះបីជាមជ្ឈមណ្ឌលការពារ និងបង្ការជំងឺ (CDC) ផ្តល់ការណែនាំថាអ្នកណាដែលគួរតែទទួលការចាក់វ៉ាក់សាំងជំងឺ កូវីដ-១៩បន្ទាប់ក៏ដោយ រដ្ឋគឺជាអ្នកដែលអាចធ្វើការសម្រេចចិត្តចុងក្រោយ។ ស្វែងរកមន្ទីរសុខាភិបាលក្នុងតំបន់របស់អ្នកនៅទីនេះ។

**តើពេលណាទើបប្រជាជនអាមេរិកភាគច្រើនអាចទទួលបានការចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩?**

រដ្ឋនីមួយៗ ជាអ្នកកំណត់ថា អ្នកណា ពេលណា និងកន្លែងណា ពាក់ព័ន្ធនឹងការចែកចាយវ៉ាក់សាំង។ នៅពេលដែលចំនួនវ៉ាក់សាំងមានការកើនឡើង ការណែនាំសម្រាប់ការចាក់វ៉ាក់សាំងនឹងត្រូវបានកែប្រែដើម្បីរួមបញ្ចូលមនុស្សកាន់តែច្រើន។ សាកសួរព័ត៌មាននៅតាមមន្ទីរសុខាភិបាលក្នុងតំបន់របស់អ្នក។ ស្វែងរកមន្ទីរសុខាភិបាលក្នុងតំបន់របស់អ្នកនៅទីនេះ។

**តើខ្ញុំអាចជ្រើសរើសប្រភេទវ៉ាក់សាំងជំងឺកូវីដ-១៩បានដែរឬទេ?**

ចំនួនវ៉ាក់សាំងអាចនឹងមានកម្រិត ហើយប្រហែលជាពិបាកក្នុងការជ្រើសរើសប្រភេទវ៉ាក់សាំង។ នៅពេលដែលយើងមានលទ្ធភាពទទួលបានការចាក់វ៉ាក់សាំងជំងឺកូវីដ-១៩ យើងគួរតែទទួលយកវ៉ាក់សាំងដែលមានសម្រាប់យើង។

**តើខ្ញុំអាចចាក់វ៉ាក់សាំងប្រភេទ PFIZER ហើយក្រោយមកចាក់វ៉ាក់សាំង MODERNA ឬវ៉ាក់សាំងប្រភេទផ្សេងទៀត សម្រាប់ការចាក់លើកទីពីរបានដែរឬទេ?**

អត់ទេ ការណែនាំបច្ចុប្បន្នគឺត្រូវចាក់វ៉ាក់សាំងប្រភេទដូចគ្នាទាំងពីរលើក។ ទទួលយកការចាក់វ៉ាក់សាំងមួយប្រភេទពីអ្នកផ្តល់សេវាមួយ ហើយត្រូវចងចាំ ឬរក្សាទុកឈ្មោះវ៉ាក់សាំងជំងឺកូវីដ-១៩ ដែលអ្នកបាន ទទួលនៅពេលអ្នកចាក់វ៉ាក់សាំងលើកទីពីរ។ សូមកុំភ្លេចស្នើសុំប័ណ្ណកំណត់ត្រាចាក់វ៉ាក់សាំងពីអ្នកផ្តល់សេវាថែទាំសុខភាពដែលគ្រប់គ្រងការចាក់វ៉ាក់សាំងរបស់អ្នក។



# ចំនួនវ៉ាក់សាំង និងលទ្ធភាពដែលអាចទទួលយកបាន

**តើខ្ញុំត្រូវមានការធានារ៉ាប់រងសុខភាពដើម្បីទទួលបានវ៉ាក់សាំងដែរឬទេ?**

ទេ វ៉ាក់សាំងជំងឺកូវីដ-១៩ គឺមិនគិតថ្លៃទេ។ អ្នកមិនចាំបាច់បង់ប្រាក់ទេ។ ទោះជាយ៉ាងណាក្តី អ្នកផ្តល់វ៉ាក់សាំងអាចនឹងគិតថ្លៃសេវារដ្ឋបាល ដែលអាចត្រូវបានទូរទាត់សងវិញដោយធានារ៉ាប់រងសាធារណៈ ឬឯកជនរបស់អ្នក ឬដោយមូលនិធិសង្គ្រោះ ប្រសិនបើអ្នកមិនមានការធានារ៉ាប់រងសុខភាព។ ត្រូវយកកាតធានារ៉ាប់រងរបស់អ្នកមកជាមួយ ប្រសិនបើអ្នកមានធានារ៉ាប់រងសុខភាព។ ប្រសិនបើអ្នកមិនមានធានារ៉ាប់រងសុខភាពទេ អ្នកនៅតែអាចទទួលបានការចាក់វ៉ាក់សាំង។

**តើវ៉ាក់សាំងអាចផ្តល់ជូនដល់សហគមន៍អន្តោប្រវេសន៍ដែលគ្មានលិខិតស្នាមដែរឬទេ?**

អាច វ៉ាក់សាំងជំងឺកូវីដ-១៩ មានផ្តល់ជូណសម្រាប់សហគមន៍ដែលគ្មានឯកសារ។ រដ្ឋបាលលោកប្រធានាធិបតីបៃដិន បានបញ្ជាក់ថានាយកដ្ឋានជនអន្តោប្រវេសន៍ និងការអនុវត្តច្បាប់របស់សហរដ្ឋអាមេរិក (ICE) និងនាយកដ្ឋានគយ និងការការពារព្រំដែនរបស់សហរដ្ឋអាមេរិក (CBP) គ្មានវត្តមាននៅកន្លែងចាក់វ៉ាក់សាំងទេ ហើយបុគ្គលិកសុខភាពសាធារណៈ មិនអាចរារាំងប្រជាជនដែលគ្មានលិខិតស្នាមពីការចាក់វ៉ាក់សាំងបានឡើយ។ អ្នកផ្តល់សេវាសុខភាពមិនគួររើសអើងទៅលើបុគ្គលលិខិតស្នាមឯកសារ ចំពោះការចាក់វ៉ាក់សាំងជំងឺកូវីដ-១៩ ទេ។ ព័ត៌មានផ្ទាល់ខ្លួនខ្លះអាចនឹងត្រូវបានស្នើសុំ ហើយព័ត៌មានផ្ទាល់ខ្លួនដែលអាចនឹងត្រូវបានស្នើសុំអាចមានភាពខុសគ្នាអាស្រ័យទៅតាមទីតាំង។ ទោះបីជាសហគមន៍អន្តោប្រវេសន៍ដែលគ្មានលិខិតស្នាមមានការភ័យខ្លាចនៅពេលផ្តល់ព័ត៌មានផ្ទាល់ខ្លួនក៏ដោយ វាពិតជាសំខាន់ណាស់ក្នុងការស្វែងរកព័ត៌មានពីសម្ព័ន្ធមិត្តសហគមន៍។ សូមប្រឹក្សាជាមួយប្រភពដែលគួរឲ្យជឿទុកចិត្តបានក្នុងសហគមន៍របស់អ្នកអំពីវិធីសាស្ត្រដែលអ្នកអាចចាក់វ៉ាក់សាំងជំងឺកូវីដ-១៩ ក្នុងរដ្ឋរបស់អ្នក និងថាតើព័ត៌មានផ្ទាល់ខ្លួនអ្វីខ្លះដែលគេត្រូវការពីអ្នក។

**តើឱសថស្ថានប្រចាំតំបន់របស់ខ្ញុំនឹងផ្តល់វ៉ាក់សាំងជំងឺកូវីដ-១៩ នៅពេលដែលមានវ៉ាក់សាំងដែរឬទេ?**

រដ្ឋាភិបាលកំពុងធ្វើការជាមួយឱសថស្ថានលក់រាយ។ ការងារនេះកំពុងដំណើរការនៅឡើយទេ។ ពិនិត្យជាមួយនាយកដ្ឋានសុខាភិបាលក្នុងតំបន់របស់អ្នកដើម្បីទទួលបានព័ត៌មានថ្មីៗបំផុត។

**តើផលប៉ះពាល់នៃវ៉ាក់សាំងជំងឺកូវីដ-១៩ មានអ្វីខ្លះ?**

ពេលខ្លះ មនុស្សមួយចំនួនអាចមានអារម្មណ៍មិនសូវស្រួលខ្លួនក្នុងអំឡុងពេល 1-2 ថ្ងៃ បន្ទាប់ពីការចាក់វ៉ាក់សាំង។ នេះគឺជារឿងធម្មតាទេ។ ផលប៉ះពាល់ទូទៅមានភាពស្រដៀងទៅនឹងផលប៉ះពាល់ដែលត្រូវបានរកឃើញជាមួយវ៉ាក់សាំងភាគច្រើន ដូចជាឈឺដៃ គ្រុនក្តៅ ហើយនឿយហត់អស់កម្លាំងក្នុងរយៈពេលពីរបីថ្ងៃ បន្ទាប់ពីចាក់វ៉ាក់សាំង។ ផលប៉ះពាល់ទាំងនេះ ជាធម្មតាមានន័យថាវ៉ាក់សាំងមានប្រសិទ្ធភាពនៅពេលវាបង្រៀនរាងកាយរបស់អ្នកឱ្យស្គាល់ ហើយប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។ ប្រសិនបើអ្នកមិនជួបប្រទះផលប៉ះពាល់ទាំងនេះទេ វាជារឿងធម្មតា វ៉ាក់សាំងជំងឺកូវីដ-១៩ កំពុងតែដំណើរការ។

ផលប៉ះពាល់ទូទៅដែលបាត់ទៅវិញក្នុងរយៈពេលខ្លីរួមមាន៖

- ឈឺចាប់នៅបរិវេណកន្លែងចាក់ថ្នាំ ហើយឡើងក្រហម
- នឿយហត់អស់កម្លាំង
- ឈឺចាប់សាច់ដុំ
- ឈឺសន្លាក់
- ឈឺក្បាល

ប្រសិនបើអ្នកមានសំណួរអំពីរោគសញ្ញា ឬផលប៉ះពាល់ណាមួយបន្ទាប់ពីអ្នកបានទទួលបានការចាក់វ៉ាក់សាំងជំងឺកូវីដ-១៩ សូមសួរទៅកាន់អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក។



**តើវ៉ាក់សាំងជំងឺកូវីដ-១៩ មានផលប៉ះពាល់អ្វីទេ ប្រសិនបើខ្ញុំកំពុងប្រើប្រាស់ថ្នាំដទៃទៀត?**
ស្វែងរកដំបូន្មានពីអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកជានិច្ច ក្នុងករណីដែលអ្នកមានសំណួរទាក់ទង
នឹងស្ថានភាពសុខភាព
ឬបើអ្នកជួបប្រទះផលប៉ះពាល់វេជ្ជសាស្ត្រអវិជ្ជមានជាមួយវ៉ាក់សាំងជំងឺកូវីដ-១៩ ។

**ចុះប្រសិនបើខ្ញុំមានផ្ទៃពោះ ឬកំពុងបំបៅកូនដោយទឹកដោះ តើខ្ញុំមានសុវត្ថិភាពក្នុងការចាក់វ៉ាក់សាំងជំងឺកូវីដ-១៩ ដែរឬទេ?**
ការធ្វើតេស្តបន្ថែមកំពុងត្រូវបានអនុវត្តដើម្បីកំណត់អំពីសុវត្ថិភាព
និងប្រសិទ្ធភាពនៃវ៉ាក់សាំងចំពោះអ្នកមានផ្ទៃពោះ។ ស្ត្រីមានផ្ទៃពោះ និងបំបៅកូនដោយទឹកដោះ
គួរតែស្វែងរកដំបូន្មានពីអ្នកផ្តល់សេវាថែទាំសុខភាពរបស់ពួកគេអំពីការចាក់វ៉ាក់សាំងជំងឺកូវីដ-១៩ ។

## អនាគតនៃវ៉ាក់សាំងជំងឺកូវីដ-១៩

**តើខ្ញុំត្រូវការចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ ញឹកញាប់ប៉ុណ្ណា?**
បច្ចុប្បន្ននេះ យើងមិនទាន់ដឹងថាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩
មានប្រសិទ្ធភាពបានយូរប៉ុណ្ណានោះទេ។ វីរុសកំពុងមានការផ្លាស់ប្តូរ ឬបម្លែងខ្លួន
ដែលអាចនឹងទាមទារឱ្យមានការចាក់វ៉ាក់សាំងឡើងវិញ។ ជាមួយគ្នាផងដែរ វ៉ាក់សាំងជំងឺកូវីដ-១៩
ប្រភេទនីមួយៗ នឹងមានតារាងពេលវេលារៀងៗខ្លួន អាស្រ័យលើរយៈពេលនៃប្រសិទ្ធភាពវ៉ាក់សាំង។
អ្នកជំនាញផ្នែកសុខភាពសាធារណៈកំពុងតែធ្វើការតាមដានយ៉ាងយកចិត្តទុកដាក់លើវីរុសនេះ
ដើម្បីស្វែងយល់បន្ថែមថាតើវ៉ាក់សាំងជំងឺកូវីដ-១៩ អាចការពារយើងបានយូរប៉ុណ្ណា
បន្ទាប់ពីយើងចាក់វ៉ាក់សាំងរួច។

**តើខ្ញុំនឹងត្រូវចាក់វ៉ាក់សាំងជំងឺកូវីដ-១៩ ជារៀងរាល់ឆ្នាំដែរឬទេ?**
នៅខណៈពេលនេះ យើងមិនទាន់ដឹងចម្លើយនៅឡើយទេ។ ដោយសារជំងឺកូវីដ-១៩
ទើបតែកើតមានថ្មី យើងមិនទាន់ដឹងថាវ៉ាក់សាំងអាចការពារពីការឆ្លងជំងឺកូវីដ-១៩
បានយូរប៉ុណ្ណាទេ។ ទោះជាយ៉ាងណាក្តី អ្នកជំនាញផ្នែកវេជ្ជសាស្ត្រ និងអ្នកជំនាញសុខភាពសាធារណៈ
បានប្តេជ្ញាចិត្តដើម្បីស្វែងយល់ព័ត៌មាននេះបន្ថែម
ហើយយើងនឹងចែករំលែកឱ្យបានឆាប់រហ័សនៅពេលទទួលបានព័ត៌មាន។

**តើខ្ញុំគួរតែចាក់វ៉ាក់សាំងជំងឺកូវីដ-១៩ ដែរឬទេ ប្រសិនបើខ្ញុំធ្វើតេស្តកូវីដ-១៩ វិជ្ជមាន?**
ត្រឹមត្រូវ។ អ្នកគួរតែចាក់វ៉ាក់សាំង ទោះបីជាអ្នកធ្លាប់បានឆ្លងជំងឺកូវីដ-១៩ ពីមុនមកហើយក៏ដោយ។
មូលហេតុដោយសារតែយើងមិនដឹងថាភាពស៊ាំធម្មជាតិមានរយៈពេលយូរប៉ុណ្ណា។
ការសិក្សាមួយចំនួនបានបង្ហាញថាវាអាចទៅរួចដែលអ្នកអាចនឹងឆ្លងជំងឺកូវីដ-១៩ ពីរដង។
យោងទៅតាមការណែនាំ អ្នកគួរតែរង់ចាំយ៉ាងហោចណាស់ឱ្យបានបួនសប្តាហ៍
បន្ទាប់ពីជាសះស្បើយពេញលេញពីការឆ្លងជំងឺកូវីដ-១៩ មុននឹងចាក់វ៉ាក់សាំងជំងឺកូវីដ-១៩។

**តើខ្ញុំត្រូវអនុវត្តតាមគោលការណ៍ការពារផ្សេងៗទេ បន្ទាប់ពីខ្ញុំចាក់វ៉ាក់សាំងជំងឺកូវីដ-១៩ រួច?**
ត្រឹមត្រូវ បន្ទាប់ពីចាក់វ៉ាក់សាំងជំងឺកូវីដ-១៩ រួច យើងគួរបន្តពាក់ម៉ាស់ អនុវត្តការរក្សាគម្លាត
ហើយលាងសម្អាតដៃជាមួយសាប៊ូ និងទឹកយ៉ាងហោចណាស់ 20 វិនាទី។
ទាំងនេះគឺជាជំហានមួយចំនួនដែលយើងអាចបន្តអនុវត្តដើម្បីបន្ថយការរីករាលដាលនៃវីរុសនៅក្នុងសហគមន៍
របស់យើង បន្ទាប់ពីយើងបានចាក់វ៉ាក់សាំងរួច។
ការអនុវត្តទាំងនេះមានសារៈសំខាន់ណាស់ដើម្បីការពារសមាជិកគ្រួសារ
និងមិត្តភក្តិដែលកំពុងរង់ចាំការចាក់វ៉ាក់សាំង។ សូមចងចាំថាវ៉ាក់សាំងតែម្យ៉ាង
មិនអាចបញ្ឈប់ការរីករាលដាលនៃការរាតត្បាតជំងឺកូវីដ-១៩ បានទេ ។
យើងត្រូវរួមបញ្ចូលវិធានការផ្សេងគ្នាជាច្រើនទៀត ដើម្បីបញ្ឈប់ការឆ្លងជំងឺកូវីដ-១៩ ។



**តើវិធានការមានសុវត្ថិភាពអ្វីខ្លះដែលខ្ញុំគួរអនុវត្ត បន្ទាប់ពីខ្ញុំបានចាក់វ៉ាក់សាំងរួច?**
បន្ទាប់ពីអ្នកបានចាក់វ៉ាក់សាំងរួច អ្នកចាំបាច់ត្រូវបន្តពាក់ម៉ាស់នៅពេលដែលអ្នកចេញទៅក្រៅ
ហើយត្រូវរក្សាគម្លាតឆ្ងាយពីអ្នកដទៃ។
ដោយសារតែអ្នកជំនាញមិនទាន់ដឹងថាតើអ្នកដែលចាក់វ៉ាក់សាំងរួចអាចផ្ទុកវីរុស
និងចម្លងមេរោគទៅអ្នកដទៃបានយ៉ាងណាទេ ដូច្នេះ
វិធានការល្អបំផុតគឺត្រូវបន្តអនុវត្តសកម្មភាពទាំងនេះដើម្បីការពារអ្នកដទៃ។

**តើមានអ្វីកើតឡើងប្រសិនបើខ្ញុំមិនចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩?**
ការចាក់វ៉ាក់សាំងនៅសហរដ្ឋអាមេរិកជាការស្ម័គ្រចិត្ត។ វាគឺជាការសម្រេចចិត្តផ្ទាល់ខ្លួនមួយ។
ប្រសិនបើអ្នកមានឱកាសដើម្បីទទួលការចាក់វ៉ាក់សាំង វានឹងជួយការពារអ្នកពីការឆ្លងជំងឺកូវីដ-១៩
ឬការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរដោយសារវីរុស។
វ៉ាក់សាំងក៏នឹងរួមចំណែកក្នុងការបង្កើនភាពស៊ាំឱ្យកាន់តែរឹងមាំ
ហើយមានករណីឆ្លងតិចតួចនៅក្នុងសហគមន៍របស់អ្នក និងនៅទូទាំងប្រទេស។
ការចាក់វ៉ាក់សាំងនឹងជួយបញ្ចប់ការរាតត្បាតឱ្យកាន់តែឆាប់រហ័ស។

ប្រភព៖
https://www.cdc.gov/coronavirus/2019-ncov/index.html

This publication was made possible by cooperative agreement CDC-RFA-IP21-2106 from the
Centers for Disease Control and Prevention of the U.S. Department of Health and Human Services (HHS).
Its contents are solely the responsibility of the authors and do not necessarily represent the official views of CDC/HHS.